# ការវាយតម្លៃរហ័សពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចសាកល ទៅលើគ្រួសារនៅកម្ពុជា៖ ឥទ្ធិពល និង យុទ្ធសាស្ត្រដោះស្រាយ*

## ១. សេចក្តីផ្តើម

កម្ពុជា ធ្លាប់រីកលូតលាស់យ៉ាងខ្លាំងដោយមានកំណើន ផសស ជាមធ្យម ប្រហែល ១១% ក្នុងរយៈពេលបីឆ្នាំបន្តបន្ទាប់ នៅមុនពេលវិបត្តិហិរញ្ញវត្ថុសាកល បានរាលដាលមកដល់កម្ពុជានៅចុងឆ្នាំ២០០៨ ។ កំណើននេះ ជំរុញឡើងជាសំខាន់ដោយវិស័យកាត់ដេរ ទេសចរណ៍ សំណង់ និង កសិកម្ម ប៉ុន្តែវាបានថយចុះមកវិញ ដោយសារការប៉ះទង្គិចមួយចំនួននៅឆ្នាំមុន ជាអាទិ៍ការឡើងថ្លៃខ្ពស់នៃអាហារ និងថាមពល ជំលោះព្រំដែនជាមួយប្រទេសថៃ និង ការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក នាពេលថ្មីៗនេះ ។ អាហារ និង ថាមពលដែលស្ទុះឡើងថ្លៃយ៉ាងខ្លាំង ចាប់ពីចុងឆ្នាំ២០០៧ រហូតដល់ពាក់កណ្តាលឆ្នាំ២០០៨ បានប៉ះពាល់ធ្ងន់ធ្ងរដល់អត្រាប្រាក់ចំណេញ ទទួលបានពីវិនិយោគ និង សុខុមាលភាពរបស់គ្រួសារនៅទូទាំងប្រទេសកម្ពុជា ។ ជំលោះព្រំដែនជាមួយថៃ បណ្តាលឱ្យមានការធ្លាក់ចុះចំនួនភ្ញៀវទេសចរ និង ការនាំចេញផលិតផលកសិកម្ម ។ រីឯ វិបត្តិសេដ្ឋកិច្ចសាកល បានប៉ះពាល់យ៉ាងខ្លាំងដល់សេដ្ឋកិច្ចកម្ពុជា ដែលពឹងផ្អែកចំបងលើការនាំចេញផលិតផលទៅទីផ្សារពិភពលោក ។ ការគន់គូរសំរាប់ឆ្នាំ២០០៩ បានបង្ហាញពីការធ្លាក់ចុះកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ (ចុះដល់ត្រឹម ២% បើតាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) រឺក៏ -០,៥% បើតាមមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)) ដោយសារវិបត្តិសេដ្ឋកិច្ចសាកល ។

មានការសិក្សាមួយចំនួនតូចបានប្រឹងប្រែងវាយតម្លៃពី ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចសាកល មកលើសេដ្ឋកិច្ចកម្ពុជា និង ផ្តល់ជាជំរើសគោលនយោបាយមួយចំនួនដែលសមស្របសំរាប់កាត់បន្ថយឥទ្ធិពលវិបត្តិ ។ ជាក់ស្តែង លោក Kang et al. (2009) បានព្យាយាមវាយតម្លៃនៅកំរិតម៉ាក្រូសេដ្ឋកិច្ច និងកំរិតតាមវិស័យ (កាត់ដេរ សំណង់ ទេសចរណ៍ និងកសិកម្ម) ព្រមទាំងស្រាវជ្រាវលំអិតពីទីផ្សារពលកម្ម និងសេដ្ឋកិច្ចតាមគ្រួសារ ។ ហើយលោក Jalilian et al. (2009) បានធ្វើការសិក្សាផ្តោតតែលើ កំរិតម៉ាក្រូសេដ្ឋកិច្ច ។ ការសិក្សាទាំងពីរបានបង្ហាញថា វិបត្តិសេដ្ឋកិច្ចសាកលបានប៉ះពាល់ធ្ងន់ធ្ងរបំផុតដល់វិស័យកាត់ដេរ (កម្មករ ៥១.០០០នាក់ ត្រូវបានបញ្ឈប់ពី ការងារ) បន្ទាប់មក គឺវិស័យសំណង់ (កម្មករ ១៥.០០០នាក់ បញ្ឈប់ពីការងារ) និងបន្ទាប់មកទៀត គឺ វិស័យទេសចរណ៍ (កំណើនធ្លាក់ដល់ -៥% នៅឆ្នាំ២០០៩) ។ វិបត្តិសេដ្ឋកិច្ចតែមួយមុខ ទំនងមិនអាចធ្វើឱ្យវិស័យកសិកម្មខូចខាតធ្ងន់ធ្ងរទេ (Jalilian et al. 2009; Kang et al. 2009) ប៉ុន្តែវិបត្តិទាំងបីខាងលើគួបផ្សំគ្នាពិតជាអាច (Theng 2009 a, b; Jalilian et al. 2009) ។

ថ្វីបើការសិក្សាមួយចំនួនពីមុននេះ ព្យាយាមស្វែងយល់ស៊ីជម្រៅពីទីផ្សារពលកម្ម និងសេដ្ឋកិច្ចតាមគ្រួសារ ប៉ុន្តែការងារភាគច្រើនផ្តោតតែលើកំរិតម៉ាក្រូសេដ្ឋកិច្ច ដោយមិនបានពិនិត្យមើលថា តើប្រជាជនត្រូវប៉ះពាល់បែបណាដោយសារវិបត្តិនានាក្រៅពីវិបត្តិសាកល និង តើពួកជនងាយរងគ្រោះបានទប់ទល់បែបណា ជាលក្ខណៈបុគ្គល គ្រួសារ និងសមូហភាព ។ គោលបំណងជាក់លាក់នៃ ការវាយតម្លៃរហ័សពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចសាកល ដែលផ្តល់ថវិកាដោយធនាគារពិភពលោក និងសម្របសម្រួលដោយក្រុមស្រាវជ្រាវរបស់វិទ្យាស្ថាន CDRI គឺ បង្ហាញពីផលប៉ះពាល់ផ្សេងៗនៃវិបត្តិសេដ្ឋកិច្ចសាកល ចំពោះបុគ្គលម្នាក់ៗ និង ចំពោះគ្រួសារ ដែលមានរួមចំណែកទាំងនៅក្នុងវិស័យរៀបរយ និងមិនរៀបរយ នៃសេដ្ឋកិច្ចកម្ពុជា ។ ការសិក្សានេះ ក៏មានបំណងផ្តល់ជូនអ្នកធ្វើផែនការ និងអ្នកកសាងគោលនយោបាយក្នុងជួររដ្ឋាភិបាល សង្គមស៊ីវិល និងដៃគូអភិវឌ្ឍ នូវព័ត៌មានសំខាន់ៗស្តីពី បែបបទដែលជនក្រីក្រ និងជនងាយរងគ្រោះ កំពុងប្រើប្រាស់ដើម្បីទប់ទល់នឹងវិបត្តិ ក្នុងពេលដែលមិនទាន់មានប្រព័ន្ធសុវត្ថិភាពសង្គមរបស់រដ្ឋាភិបាល ។

## ២. វិធីសាស្ត្រស្រាវជ្រាវ

ដើម្បីស៊ើបសួរពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចសាកល ទៅលើបុគ្គល និងគ្រួសារ ការសិក្សានេះបានប្រើវិធីសាស្ត្របែបគុណភាព ដោយធ្វើសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ ឬសម្ភាសន៍ពាក់កណ្តាលរៀបរយ (Semi-Structured Interview—SSIs) និងការពិភាក្សាតាមក្រុមស្នូល (FGD) និងបានប្រើឧបករណ៍ ខ្សែបន្ទាត់ពេល (time-line) ដើម្បីស្វែងយល់ស៊ីជម្រៅពីបទពិសោធន៍ដែលអ្នកផ្តល់ព័ត៌មានបានឆ្លងកាត់ក្នុងរយៈពេល ១២ខែ និង ៦ខែ មុនពេល ធ្វើការវាយតម្លៃនេះ (ខែឧសភា ២០០៩) ។ SSIs ត្រូវបានធ្វើឡើងជាមួយបុគ្គលពីររូប ដែលជ្រើសរើសដោយមានគោលដៅចេញពីក្រុមជនងាយរងគ្រោះ[១] (បូកនឹងកម្មករកាត់ដេរ ចំនួន ៥នាក់) និង

---

* អត្ថបទនេះ រៀបចំដោយ បណ្ឌិត ថេង វុទ្ធី និង លោក គឹម សុធន ។ បណ្ឌិត ថេង វុទ្ធី ជាអ្នកសម្របសម្រួលកម្មវិធី ភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ នៅ CDRI ហើយ លោក គឹម សុធន ជាអ្នកស្រាវជ្រាវក្នុងកម្មវិធីជាមួយគ្នា ។ អត្ថបទនេះ ជាសេចក្តីសង្ខេបនូវលទ្ធផលរកឃើញជាក់ស្តែង ក្នុងការវាយតម្លៃរហ័សពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចសាកល ទៅលើគ្រួសារនៅកម្ពុជា ដែលធ្វើឡើយដោយក្រុមស្រាវជ្រាវ របស់ CDRI កាលពីខែឧសភា ២០០៩ ដោយទទួលថវិកាពីធនាគារពិភពលោក ។

១ កម្មករងាយរងគ្រោះ គឺមាន អ្នកធាក់ស៊ីក្លូ អ្នករត់ម៉ូតូឌុប អ្នកលីសែង កម្មករសំណង់មានជំនាញ និងគ្មានជំនាញ អ្នកបំរើតុភោជនីយដ្ឋាន កម្មករកាត់ដេរ អ្នករើសអេតចាយ និងអ្នកលក់បន្លែតូចតាច (ក្នុងទីក្រុងភ្នំពេញ) កសិករ (ភូមិប៉ៃលហែល ខេត្តកំពង់ស្ពឺ និង ភូមិដូនវង្ស ខេត្តកណ្តាល) អ្នករត់ម៉ូតូទុកទុក បុគ្គលិកភោជនីយដ្ឋាននិងសណ្ឋាគារ (ខេត្តសៀមរាប) និង ជនចំណាកស្រុក (ភូមិអណ្តូងត្រាច និង ក្រសាំង ខេត្តបាត់ដំបង) ។

គ្រួសារក្រីក្រនៅតាមជនបទក្នុងការសិក្សាពីឱណាមិកនៃភាពក្រីក្រ[២] (PDS) និង មេភូមិ ៩នាក់ ដែលសរុបមកបាន ៥៦ SSIs ។ រីឯ FGDs វិញ ត្រូវបានធ្វើឡើងជាមួយ ១៣ ក្រុមពលករងាយរងគ្រោះ គឺមាន អ្នកធាក់ស៊ីក្លូ អ្នករត់ម៉ូតូទុកទុក និងអាជីវករតូចតាច, កម្មករសំណង់មានជំនាញ និងគ្មានជំនាញ កម្មករកាត់ដេរ អ្នកស៊ីឈ្នួលធ្វើស្រែនៅភូមិដូនវង្ស និង គ្រួសារក្រីក្រនៅភូមិអណ្តូងត្រាច ក្រសាំង ត្រពាំងព្រៃ កំពង់ត្នោត និង បាបោង ។ របកគំហើញនៃការសិក្សា បង្ហាញត្រឹមតែបទពិសោធន៍របស់ក្រុមគំរូតាងទាំងនេះប៉ុណ្ណោះ ដូច្នេះ ត្រូវប្រុងប្រយ័ត្នទៅពេលយកទិន្នន័យនេះទៅប្រើប្រាស់ជារួមសំរាប់ក្រុមដទៃទៀត ។

## ៣. របកគំហើញផ្អែកលើពិសោធន៍ជាក់ស្តែង

### ៣.១. ឥទ្ធិពលនៃវិបត្តិ ទៅលើ បុគ្គល និង គ្រួសារ

*ការងារ ប្រាក់ចំណូល និង ប្រាក់ផ្ញើទៅផ្ទះ*

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ វិស័យរៀបរយដែលជំរុញ កំណើនសេដ្ឋកិច្ច (កាត់ដេរ សំណង់ និងទេសចរណ៍) បានផ្តល់ការងារដល់ពលករ រាប់រយពាន់នាក់ ដែលធ្វើចំណាកស្រុក មកពីតំបន់ជនបទផ្សេងៗនៅកម្ពុជា និង បានជួយកែលំអជីវភាពរស់នៅរបស់ពួកគេ ។ ប៉ុន្តែ សុខុមាលភាពរបស់ពលករ និងគ្រួសាររបស់អ្នកទាំងនេះ មិនមាំទាំទេ នៅពេលមានការប៉ះទង្គិចមិនអាចដឹងមុន ។ ពលករក្នុងវិស័យ សេដ្ឋកិច្ចមិនរៀបរយ ក៏ងាយរងគ្រោះដូចពលករក្នុងវិស័យរៀបរយដែរ នៅចំពោះមុខស្ថានភាពមិនប្រាកដប្រជានៃការងារ និងប្រាក់ចំណូល ។

ព័ត៌មានទទួលបានពី SSIs និង FGDs បង្ហាញពីនិន្នាការជាទូទៅមួយនៃការថយចុះចំនួនការងារ ទាំងនៅទីក្រុងភ្នំពេញ និងតំបន់ជនបទ ប្រហែលពី ៣០%-៤០% ក្នុងរយៈពេល ៦ខែចុងក្រោយ និងថយចុះប្រហែល ៧០% ក្នុងផ្នែកសាងសង់ ។ ការធ្លាក់ចុះសេដ្ឋកិច្ច បានប៉ះពាល់ច្បាស់ណាស់ទៅលើវិស័យកាត់ដេរ សំណង់ និងទេសចរណ៍ និងប៉ះពាល់មួយកំរិតទៅលើវិស័យកសិកម្ម ។ ឧទាហរណ៍ កម្មករកាត់ដេរកំពុងបំរើការងារ បានរាយការណ៍ពីការបាត់បង់ការងារម៉ោងបន្ថែម ឬ ការកាត់បន្ថយចំនួនថ្ងៃធ្វើការ ដែលជាបញ្ហាបារម្ភធំមួយ ព្រោះវាប៉ះពាល់យ៉ាងខ្លាំងទៅលើចំណូលប្រចាំខែរបស់កម្មករ ។ ក្នុងរយៈពេល ៦ខែកន្លងទៅនេះ ពួកកម្មករមិនអាចសន្សំប្រាក់ផ្ញើទៅផ្ទះបានទេ ដោយសារចំណូលប្រចាំខែរបស់ពួកគេ ស្ទើរតែមិនគ្រប់សំរាប់ដោះស្រាយចំណាយប្រចាំថ្ងៃរបស់ខ្លួនបានផង ។

ចំនួនការងារដែលមានសំរាប់កម្មករសំណង់ (កម្មករមានជំនាញ និងគ្មានជំនាញ) នៅរាជធានីភ្នំពេញ និងខេត្តបាត់ដំបង បានធ្លាក់ចុះយ៉ាងច្រើនក្នុង ៦ខែមុននេះ ។ចំណូលប្រចាំថ្ងៃរបស់កម្មករសំណង់គ្មានជំនាញ នៅទីក្រុងភ្នំពេញ មានលក្ខណៈមិនទៀងទាត់ឡើយ ដោយនៅថ្ងៃខ្លះអាចរកចំណូលបាន និងថ្ងៃខ្លះទៀត គ្មានការងារធ្វើទេ ។ ជាលទ្ធផល ទោះបីជាអត្រាប្រាក់កំរៃការងារនៅថេរក៏ដោយ ក៏ប្រាក់ចំណូលរបស់ពួកគេ ស្ទើរតែមិនគ្រប់សំរាប់ដោះស្រាយចំណាយ លើការរស់នៅប្រចាំថ្ងៃក្នុងទីក្រុងផង ហើយពួកគេមិនអាចសន្សំប្រាក់សំរាប់ផ្ញើទៅជួយក្រុមគ្រួសារបានទេ ។ ចំណូលប្រចាំខែរបស់កម្មករសំណង់មានជំនាញ ក៏បានថយចុះដែរ ដោយសារការថយចុះចំនួនការងារដែលមាន ។ ប៉ុន្តែកម្មករមានជំនាញ មិនសូវងាយរងគ្រោះដូចកម្មករគ្មានជំនាញទេ (កម្មករទូទៅដែលធ្វើការនៅតាមការដ្ឋានសំណង់កំពុងដំណើរការ) ដោយសារទីផ្សារនៅមានតំរូវការពលកម្មរបស់ពួកគេ ។ កម្មករមានជំនាញក៏ទទួលប្រាក់កំរៃ ច្រើនជាង កម្មករគ្មានជំនាញដែរ ហើយពួកគេអាចសន្សំប្រាក់ បានច្រើនជាង ពួកកម្មករទូទៅ (១០០.០០០-១៥០.០០០៛ ក្នុង១ខែ) ។

ចំនួនថ្ងៃធ្វើការរបស់បុគ្គលិក សណ្ឋាគារ និងភោជនីយដ្ឋាន នៅខេត្តសៀមរាប បានធ្លាក់ចុះ ៣០-៤០% ដោយសារការធ្លាក់ចុះចំនួនអតិថិជនអស់ ២០-៣០% ។ បុគ្គលិកទាំងនេះ ត្រូវធ្វើការខ្លាំងជាងមុន ដោយសារបុគ្គលិកបណ្តែតជាច្រើនត្រូវបានបញ្ឈប់ពីការងារ ។ ទោះបីក្នុងរយៈពេល ៦ខែកន្លងទៅនេះ ពួកគេត្រូវធ្វើការច្រើនជាងមុនក៏ដោយ ប៉ុន្តែពួកគេទទួលបានចំណូលដដែល គឺ បានជាមធ្យម ៦៥-១០០ដុល្លារអាមេរិក បូកទាំងប្រាក់ទឹកតែបានពីភ្ញៀវផង ។ ពួកគេមិនអាច ឬអាចសន្សំប្រាក់បានតិចតួចសំរាប់ផ្ញើទៅឱ្យឪពុកម្តាយ រឺក្រុមគ្រួសារនៅផ្ទះ ហើយប្រាក់នេះមិនបានទៀងទាត់ដូចកាលពីមុនឡើយ ។

កម្មករចំណាកស្រុក ដែលបំរើការក្នុងចំការដំឡូងឈើ ពោត សណ្តែក ផ្លែឈើផ្សេងៗ និង ចំការកៅស៊ូ បានជួបនឹងការធ្លាក់ចុះតម្រូវការពលកម្មទាំងនៅប្រទេសថៃ និងនៅប្រទេសកម្ពុជា ដោយសារទំនាស់ព្រំដែន និងការថយចុះកំរិតថ្លៃ និងបរិមាណនាំចេញកសិផល ។ ក្នុងរយៈពេល ៦ខែកន្លងទៅនេះ ប្រាក់ចំណូលរបស់ពួកគេ ធ្លាក់ចុះជាខ្លាំង ដោយសារមានការងារតិច និងការថយចុះប្រាក់កំរៃពលកម្ម ពី ៣០០បាត/ថ្ងៃ (៣៥៦៥០៛/ថ្ងៃ) មកត្រឹម ១២០បាត/ថ្ងៃ (១៤២៦០៛/ថ្ងៃ) ហើយ ប្រាក់ផ្ញើទៅផ្ទះក៏ថយចុះអស់ពាក់កណ្តាលដែរ ។

ការងារដែលមានសំរាប់កម្មករ និងអាជីវករតូចតាច ក្នុងវិស័យសេដ្ឋកិច្ចមិនរៀបរយ បានធ្លាក់ចុះយ៉ាងខ្លាំង ។ ប្រាក់ចំណូលរបស់អ្នករត់ម៉ូតូទុកទុក នៅខេត្តសៀមរាប បច្ចុប្បន្នបានធ្លាក់ចុះមកត្រឹម ១០.០០០-៣០.០០០៛ ធៀបនឹងចំណូលរហូតដល់ ៦០.០០០៛/ថ្ងៃ កាលពីមុន ដោយសារការធ្លាក់ចុះយ៉ាងខ្លាំងនៃចំនួនភ្ញៀវទេសចរបរទេស និងក្នុងស្រុក គួបផ្សំនឹងកំណើនចំនួនអ្នករត់ម៉ូតូទុកទុក ក្នុងរយៈពេល ៦ខែកន្លងទៅនេះ ។ ចំណូលប្រចាំថ្ងៃរបស់អ្នកធាក់ស៊ីក្លូ ក៏បានធ្លាក់ចុះអស់ជិត ៣០% ដែរ គឺពី ៧.០០០៛/ថ្ងៃ មកត្រឹមប្រហែល ៥.០០០៛/ថ្ងៃ ដោយសារការថយចុះចំនួនអតិថិជន ។ អ្នករត់ម៉ូតូទុកទុក និងអ្នកធាក់ស៊ីក្លូភាគច្រើន បានធ្វើចំណាកស្រុកមកពីទីជនបទ ដូច្នេះការធ្លាក់ចុះប្រាក់ចំណូលប្រចាំថ្ងៃបានប៉ះពាល់យ៉ាងខ្លាំងដល់ទឹកប្រាក់ផ្ញើទៅផ្ទះ ។ អាជីវករតូចតាចនៅខេត្តសៀមរាប បានរាយការណ៍ពីការធ្លាក់ចុះប្រាក់ចំណូលយ៉ាងខ្លាំង (លើសពី ៥០% ក្នុងរយៈពេល៦ខែ

២ ភូមិដែលជាគោលដៅនៃ PDS មាន : ភូមិអណ្តូងត្រាច និង ក្រសាំង (ខេត្តបាត់ដំបង) ភូមិខ្សាច់ជីរស់ និង ដងក្តារ (ខេត្តកំពង់ធំ) ភូមិកញ្ជរ (ខេត្តក្រចេះ) ភូមិព្រៃកក្មេង (ខេត្តកណ្តាល) ភូមិបាបោង (ខេត្តព្រៃវែង) ភូមិត្រពាំងព្រៃ (ខេត្តកំពង់ស្ពឺ) និង ភូមិកំពង់ត្នោត (ខេត្តកំពត) ។

ចុងក្រោយ) ពី ១០០.០០០៛/ថ្ងៃ មកត្រឹម ៤០.០០០-៥០.០០០៛/ថ្ងៃ ដោយសារការថយចុះភ្ញៀវទេសចរ និងកំណើនចំនួនអាជីវករ ពីព្រោះពួកកម្មករដែលបាត់បង់ការងារក្នុងវិស័យផ្លូវការ បានមកប្រកបរបរនេះដែរ ។ អ្នកលក់បន្លែតូចតាច នៅរាជធានីភ្នំពេញ បានរាយការណ៍ដូចគ្នាពីការធ្លាក់ចុះប្រាក់ចំណូលយ៉ាងខ្លាំង ដោយសារមានអតិថិជនតិចជាងមុន ហើយពួកអ្នកទិញស្វែងរកទំនិញថោកៗ និងតថ្លៃខ្លាំងជាងមុន ។ អ្នកលីសែងនៅតាមទីផ្សារ បានធ្លាក់ចុះប្រាក់ចំណូលអស់ ២០-៤០% ដោយសារការថយចុះ តំរូវការសេវាកម្មរបស់ពួកគេ ។ ការផ្លាស់ប្តូរឥរិយាបថក្នុងការចាយវាយរបស់ប្រជាជនទីក្រុង និងជនបទ កំពុងបង្កបំរែបំរួលក្នុងប្រាក់ចំណូលរបស់អ្នករើសអេតចាយនៅកន្លែងចាក់សំរាមស្ទឹងមានជ័យ និងកន្លែងឯទៀតៗ ។ ប្រាក់ចំណូលរបស់ក្រុមនេះ ស្ទើរតែមិនគ្រប់សំរាប់ដោះស្រាយចំណាយប្រចាំថ្ងៃផង ហើយពួកគេមិនមានលទ្ធភាព ឬមានលទ្ធភាពតិចតួចបំផុតក្នុងការសន្សំប្រាក់សំរាប់ផ្ញើទៅផ្ទះនៅតាមទីជនបទ ។

## *ការងារនៅជនបទ និងចំណូលគ្រួសារ*

ការលក់ដីនៅតាមតំបន់ផ្សេងៗក្នុងប្រទេសកម្ពុជា នៅអំឡុងពេលដីឡើងថ្លៃខ្ពស់ រហូតមកទល់ឆ្នាំ២០០៧ គឺជាកត្តាចំបងមួយនៃការថយចុះចំនួនការងារក្នុងវិស័យកសិកម្ម ប៉ុន្តែវិបត្តិសាកល ក៏មានចំណែកក្នុងបញ្ហានេះដែរ ។ ចាប់តាំងពីវិបត្តិបានផ្ទុះឡើងនៅចុងឆ្នាំ២០០៨ តំរូវការកំលាំងពលកម្មក្នុងវិស័យកសិកម្ម (ជាពិសេស ពលករស៊ីឈ្នួលធ្វើស្រែ) នៅតាមភូមិបានធ្លាក់ចុះអស់ ៣០-៤០% ហើយប្រាក់កំរៃប្រចាំថ្ងៃរបស់ពលករស៊ីឈ្នួលធ្វើស្រែ បានថយចុះអស់ប្រហែល ៣០-៥០% ។ កសិករដំណាំស្រូវ ត្រូវធ្វើការដាំដុះលើដីរបស់ខ្លួនឯងផ្ទាល់ ពីព្រោះពុំមានប្រាក់សំរាប់ជួលពលករផ្សេងទៀត ដោយសារការថយចុះប្រាក់ផ្ញើមកពីសមាជិកគ្រួសារទៅធ្វើការខាងកាត់ដេរ និងសំណង់ និងដែលបានត្រលប់មកផ្ទះមួយរយៈ ដើម្បីជួយការងារក្នុងរដូវធ្វើស្រែ ។ អ្នកភូមិដែលបានលក់ដីដាំដុះនៅអំឡុងពេលមានកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងឆ្នាំ២០០៧-២០០៨ បានផ្លាស់ប្តូរពីការងារធ្វើស្រែ ទៅធ្វើជាអ្នកលក់ពលកម្មនៅក្នុងភូមិរបស់ខ្លួន ឬក៏ធ្វើចំណាកស្រុកទៅរកការងារនៅទីក្រុង ។ អ្នកទាំងនេះភាគច្រើនជាគ្រួសារគ្មានដីធ្លី ឬមានដីតិចតួច ដែលពឹងពាក់ខ្លាំងលើប្រាក់ផ្ញើពីសមាជិកគ្រួសារចេញទៅបំរើការ ក្នុងវិស័យកាត់ដេរ ឬសំណង់ ។ ជាភ័ព្វអាក្រក់ ប្រាក់ផ្ញើមកផ្ទះបានថយចុះអស់ប្រហែល ៥០% ដោយមានការងារតិច ហើយចំណូលដែលរកបានក្នុងភូមិស្រុក ក៏ថយចុះយ៉ាងខ្លាំងដែរដោយសារការប្រកួតប្រជែងខ្លាំងក្នុងចំណោមអ្នកភូមិ ។ អ្នកទាំងនេះជាក្រុមងាយរងគ្រោះខ្លាំងជាងគេដោយសារវិបត្តិសេដ្ឋកិច្ចសាកល ដូចជា ពួកគ្រួសារក្រីក្រនៅជនបទក្នុងភូមិត្រពាំងព្រៃ និង ប៉ៃលហែល ក្នុងខេត្តកំពង់ស្ពឺ និង ភូមិដូនវង្សក្នុងខេត្តកណ្តាល ជាដើម ។

ចំពោះអ្នកភូមិមានដីស្រែវិញ វិបត្តិសាកលហាក់ដូចគ្រាន់តែជាកត្តាមួយក្នុងចំណោមកត្តាជាច្រើន ដែលជះឥទ្ធិពលទៅលើសេដ្ឋកិច្ចគ្រួសាររបស់ពួកគាត់ ហើយដែលមិនសូវធំដុំដូចហានិភ័យផ្សេងៗទៀត ដូចជា គ្រោះរាំងស្ងួត ការបំផ្លិចបំផ្លាញដោយសត្វចង្រៃ ការរិចរិលធនធានធម្មជាតិ កំណើនចំណាយលើធាតុចូល និងការធ្លាក់ថ្លៃផលដំណាំ ជាដើម ។ ក្នុងរយៈពេល ៦ខែ កន្លងទៅនេះ នៅភូមិ បាបោង អណ្តូងត្រាច និង ក្រសាំង ប្រាក់ចំណូលរបស់គ្រួសារដែលទទួលបានជាចំបងពី ផលស្រូវប្រាំង ឬផលស្រូវវស្សា និងការងារចំណាកស្រុក បានធ្លាក់ចុះ ដោយសារការកើតសត្វចង្រៃបំផ្លាញផលដំណាំ និងភ្លៀងធ្លាក់ខ្លាំងនៅពេលច្រូតកាត់ គួបផ្សំនឹងអង្ករធ្លាក់ថ្លៃ ។ គ្រួសារដែលរកចំណូលពីការនេសាទ ការធ្វើស្រែ និងការងារចំណាកស្រុក ត្រូវបានប៉ះពាល់ធ្ងន់ធ្ងរ ដោយសារការរិចរិលធនធានសមុទ្រ គ្រោះរាំងស្ងួត និងការធ្លាក់ចុះសេដ្ឋកិច្ច ។ ឧទាហរណ៍ នៅភូមិកំពង់ត្នោតត្រីចាប់បានវាធ្លាក់ចុះយ៉ាងខ្លាំង ដោយសារសកម្មភាពនេសាទខុសច្បាប់ ហើយទិន្នផលស្រូវក៏បានធ្លាក់ចុះអស់ ៥០% ដោយសារគ្រោះរាំងស្ងួតនៅឆ្នាំ២០០៨។ ក្រុមគ្រួសារដែលមានដីស្រែ និងពឹងផ្អែកលើប្រាក់ផ្ញើពីសមាជិកគ្រួសារដែលធ្វើចំណាកស្រុក បានទទួលរងឥទ្ធិពលពីវិបត្តិសេដ្ឋកិច្ចក្នុងកំរិតមួយ ដោយសារការថយចុះចំនួនការងារនៅទីក្រុង ។

## *សន្តិសុខការងារ និងការប្រកួតប្រជែង*

ពលករងាយរងគ្រោះដែលឆ្លើយសម្ភាសន៍ បានសម្តែងការព្រួយបារម្ភជាខ្លាំងពីសន្តិសុខការងារ និង សមត្ថភាពប្រកួតប្រជែង ។ ពលករធ្វើស្រែដែលជាសមាជិកគ្រួសារក្រីក្រ ត្រូវពឹងផ្អែកយ៉ាងខ្លាំងលើការលក់កំលាំងពលកម្ម ដូច្នេះសន្តិសុខការងារជាកត្តាសំខាន់បំផុត ពីព្រោះក្នុងរយៈពេល ៦ខែកន្លងមកនេះ ចំនួនការងារនៅក្នុង និងនៅក្រៅកសិដ្ឋាន បានថយចុះយ៉ាងច្រើនទាំងនៅក្នុងភូមិ និងនៅក្រៅភូមិ ។ អ្នកធាក់ស៊ីក្លូមានការបារម្ភណាស់ចំពោះការប្រកួតប្រជែងយ៉ាងខ្លាំងពីសំណាក់អ្នករត់ម៉ូតូទុកទុក និងអ្នករត់ម៉ូតូឌុប ដែលបានធ្វើឱ្យប្រាក់ចំណូលរបស់ពួកគាត់ធ្លាក់ចុះ ។ កម្មករកាត់ដេរ ក៏បារម្ភណាស់ដែរពីសន្តិសុខការងារ និងការប្រកួតប្រជែងនៅកន្លែងធ្វើការ ។ ក្នុងរយៈពេល៦ខែ កន្លងទៅ ពួកគេមិនអាចតវ៉ាពីការកាត់បន្ថយការងារម៉ោងបន្ថែម និងចំនួនថ្ងៃធ្វើការបានទេ ។ បើសិនចង់ធ្វើការបន្តទៀត គឺត្រូវបង្ខំចិត្តទទួលយកប្រាក់ចំណូលប្រចាំខែតិចជាងមុន ។ កម្មករសំណង់មានជំនាញ និងគ្មានជំនាញ កំពុងបារម្ភថា អាចពិបាកនឹងរកការងារថ្មីធ្វើ នៅពេលការងារបច្ចុប្បន្នចប់អស់ទៅ ។ ក្នុងរយៈពេល ៦ខែនេះដែរ ចំនួនអ្នករត់ម៉ូតូទុកទុក និងអាជីវករតូចតាចនៅខេត្តសៀមរាប បានកើនឡើងយ៉ាងច្រើន ដោយសារពលករដែលបាត់បង់ការងារ និងបុគ្គលិកសណ្ឋាគារ និងភោជនីយដ្ឋាននៅក្រោយម៉ោងធ្វើការ បាននាំគ្នាចាប់យករបរទាំងនេះដែរ ។ សភាពការណ៍នេះគួបផ្សំនឹងការធ្លាក់ចុះយ៉ាងច្រើននៃចំនួនភ្ញៀវទេសចរបរទេស និងក្នុងស្រុក បានបង្កជាការប្រកួតប្រជែងគ្នាយ៉ាងខ្លាំង ហើយជាលទ្ធផល ប្រាក់ចំណូលប្រចាំថ្ងៃ និងប្រាក់ផ្ញើទៅផ្ទះរបស់ពួកគេ បានធ្លាក់ចុះគួរឱ្យកត់សំគាល់ ។

## *ការជាប់បំណុល*

អសមត្ថភាពក្នុងការសងបំណុល ជាបញ្ហាមួយដែល ជនក្រីក្រ និងងាយរងគ្រោះ កំពុងព្រួយបារម្ភជាខ្លាំង ។ អ្នកឆ្លើយសំភាសន៍ បានរាយការណ៍ គ្រប់គ្នាពីការជាប់បំណុលយ៉ាងក្រាស់ក្រែល ជាមួយប្រភពផ្តល់កំចីផ្សេងៗ ដូចជា អ្នកផ្តល់កំចីឯកជន សាច់ញាតិ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFIs) ជាដើម ។ ការធ្វើសម្ភាសន៍ បានឱ្យដឹងថា បំណុលភាគច្រើនបានខ្ចីគេ

លើសពី៦ខែទៅហើយ ហើយវាបានកើនឡើងថែមទៀតក្នុងរយៈពេល ៦ខែកន្លងទៅនេះ ។ ពួកគេបានយកប្រាក់កំចីទាំងនោះ ទៅចំណាយលើការថែទាំសុខភាព ឬធ្វើបុណ្យសព្វ សាងសង់ឬជួសជុលផ្ទះសម្បែង ទិញម្ហូបអាហារ ទិញធាតុចូលកសិកម្ម សងបំណុលចាស់ៗ ឬប្រើជាសោហ៊ុយនៅពេលធ្វើចំណាកស្រុក ។ ដោយសារប្រាក់ចំណូលបានធ្លាក់ចុះ ជនក្រីក្រ និងពលករងាយរងគ្រោះដែលឆ្លើយសម្ភាសន៍ មិនអាចសងបំណុលបានទេ ដូច្នេះក៏ត្រូវបង្ខំចិត្តលក់ដោះទ័លនូវទ្រព្យសម្បត្តិ ដូចជា ដីស្រែ ឬ ផ្ទះ ជាដើម (ករណីនេះកើតមានធ្ងន់ធ្ងរ នៅភូមិដូនវង្ស ត្រពាំងព្រៃ និងកំពង់ត្នោត) ។ ឧទាហរណ៍ ប្រធានភូមិត្រពាំងព្រៃបានប្រាប់ថា ចំនួនអ្នកខ្ចីប្រាក់ពីស្ថាប័នមីក្រូហិរញ្ញវត្ថុ កើនឡើង ៥០% ក្នុងរយៈពេល ៦ខែកន្លងទៅ ។ មានគ្រួសារតិចតួចណាស់ដែលអាចសងបំណុលគេវិញ និងមានប្រជាជនមួយចំនួនបានបាត់ខ្លួនពីភូមិ ។ ករណីស្រដៀងគ្នានេះ ក៏ឃើញមានរាយការណ៍ដែរ នៅភូមិបាបោង និង ក្រសាំង ដែលនៅទីនោះ ការធ្វើចំណាកស្រុក បានក្លាយជាប្រភពរកការងារ និងប្រាក់ចំណូល ដើម្បីសងបំណុល ។

### *ការភ័យខ្លាចបទល្មើសព្រហ្មទណ្ឌ*

ភាពភ័យខ្លាចបទល្មើសព្រហ្មទណ្ឌ និងការព្រួយបារម្ភពីសុវត្ថិភាព នៅតែជាឧបសគ្គរាំងដល់លទ្ធភាពរបស់អ្នកជនបទ និងជនចំណាកស្រុកនៅទីក្រុងក្នុងការប្រកបរបរចិញ្ចឹមជីវិត ។ បទព្រហ្មទណ្ឌ រួមមាន ការលួចឆក់ ការប្លន់ម៉ូតូ និងការបោកប្រាស់ដែលមានដូចជា ការមិនឱ្យប្រាក់ឈ្នួល ជាពិសេសចំពោះកម្មករសំណង់គ្មានជំនាញ និង មានជំនាញ ។ ការព្រួយបារម្ភនេះមានខ្លាំង ឬតិចទៅតាមភូមិស្រុក ទីកន្លែងធ្វើការ និងប្រភេទពលករ ប៉ុន្តែពួកមេភូមិ FGDs និងពលករងាយរងគ្រោះ បាននិយាយដល់វាជារឿយៗ ។ ចាប់ពីចុងឆ្នាំ២០០៨ ករណីលួចប្លន់ បានកើតមានកាន់តែញឹកញាប់ចំពោះកម្មករកាត់ដេរ ។ ពលករគ្មានជំនាញ អ្នកធាក់ស៊ីក្លូ និងអ្នកលីសែង ច្រើនតែនៅផ្តុំគ្នាជាក្រុមធំៗ ក្នុងនេះពួកកម្មករសំណង់គ្មានជំនាញតែងមានអារម្មណ៍សុខសប្បាយជាង បើសិនគេអនុញ្ញាតឱ្យស្នាក់នៅក្នុងការដ្ឋានសាងសង់ ។ ដោយឡែកពួកអ្នករត់ម៉ូតូឌុប និងអ្នករត់ម៉ូតូទុកទុក នៅតែងាយរងគ្រោះដោយសារបទល្មើសទាំងនេះនៅឡើយ ។

## ៣.២. យុទ្ធសាស្ត្រដោះស្រាយ

នៅពេលជីវភាពរស់នៅរបស់ខ្លួនត្រូវជួបនឹងការប៉ះទង្គិច ឬករណីអសន្តិសុខផ្សេងៗ ពលករងាយរងគ្រោះ និងគ្រួសារនៅតាមជនបទ បានប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយច្រើនបែបយ៉ាង ។ យុទ្ធសាស្ត្រជាទូទៅមួយចំនួនដែលទទួលបានពី SSIs និង FGDs មានដូចតទៅ ។

### *ការកាត់បន្ថយចំណាយប្រើប្រាស់*

ពលករងាយរងគ្រោះដែលត្រូវប្រើកំលាំងកាយដើម្បីធ្វើការ ដូចជា អ្នកធាក់ស៊ីក្លូ ពលករចំណាកស្រុក និង កម្មករសំណង់ ជាដើម គឺមិនបានកាត់បន្ថយបរិមាណអាហារទេ ប៉ុន្តែបានបន្ថយគុណភាពអាហារវិញ ពីព្រោះម្ហូបអាហារបានឡើងថ្លៃខ្លាំង[៣] ។ កម្មករសំណង់មានជំនាញ មិនបានបង្ហាញពីការកាត់បន្ថយអ្វីច្បាស់លាស់ នូវចំណាយប្រើប្រាស់លើទំនិញមិនមែនម្ហូបអាហារនោះទេ ប៉ុន្តែបានបង្កើនចំណាយលើការធ្វើដំណើរ ដោយពួកគេតែងធ្វើដំណើរទៅផ្ទះញឹកញាប់ជាងមុន នៅពេលមិនសូវមានការងារធ្វើនៅទីក្រុង ព្រោះពួកគេនៅសល់ប្រាក់ច្រើនគួរសម សម្រាប់ការធ្វើដំណើរ ។ ចំពោះកម្មករសំណង់គ្មានជំនាញ ពលករចំណាកស្រុក និងអ្នកធាក់ស៊ីក្លូវិញ ពួកគេបានកាត់បន្ថយចំណាយធ្វើដំណើរ ដើម្បីសំចៃប្រាក់ ព្រោះពុំមានលទ្ធភាពដោះស្រាយសោហ៊ុយធ្វើដំណើរ ដោយសារប្រាក់ចំណូលធ្លាក់ចុះខ្លាំងណាស់ ។ ពួកគេក៏បានកាត់បន្ថយច្រើនដែរ នូវចំណាយលើទំនិញមិនមែនអាហារ ដូចជា សំលៀកបំពាក់ ស្រា បារី ជាដើម ។ ក្រុមពលករងាយរងគ្រោះដទៃទៀត ក៏បានរាយការណ៍ដូចគ្នា ពីការកាត់បន្ថយចំណាយប្រើប្រាស់ ទាំងលើទំនិញ ជាអាហារ និងមិនមែនអាហារ ដែលជាមធ្យោបាយទី១សំរាប់ទប់ទល់នឹងវិបត្តិ ។

គ្រួសារក្រីក្រនៅជនបទ បានកាត់បន្ថយចំណាយលើអាហារ និងទំនិញមិនមែនអាហារ ដោយសារចំណូលរបស់ គ្រួសារធ្លាក់ចុះជាខ្លាំង ក្នុងរយៈពេល ៦ខែកន្លងមកនេះ ។ បម្រែបម្រួលចំណាយប្រើប្រាស់លើម្ហូបអាហារ អាចមើលឃើញច្បាស់ ទាំងតាមចំនួនទឹកប្រាក់បានចំណាយ និង គុណភាព ឬប្រភេទអាហារដែលបានទិញ (ឧ. ការផ្លាស់ប្តូរពី ទិញសាច់ជ្រូក ឬត្រីធំៗ ទៅទិញកូនត្រីតូចៗវិញ) ។ ក្នុងគ្រួសារនៅតាមជនបទ និងគ្រួសាររបស់ពលករងាយរងគ្រោះ ការកាត់បន្ថយចំណាយប្រើប្រាស់នេះប៉ះពាល់ខ្លាំងជាងគេទៅលើឪពុកម្ដាយ និង តិចជាងគេទៅលើកុមារតូចៗ ។

### *កំណើនបន្ទុកការងារ*

វិបត្តិសេដ្ឋកិច្ចសាកល បានពាល់ធ្ងន់ធ្ងរដល់ពលករងាយរងគ្រោះ និងគ្រួសារនៅជនបទ តាមរយៈការថយចុះចំនួនការងារ ប្រាក់ចំណូល ប្រាក់ផ្ញើមកផ្ទះ និងសន្តិសុខការងារ ។ អ្នកឆ្លើយសម្ភាសន៍ជាច្រើនរាយការណ៍ថា ពួកគេត្រូវធ្វើការងារមិនទៀងទាត់ថែមទៀត បន្ទាប់ពីចប់ម៉ោងការងារផ្លូវការ ដើម្បីរកប្រាក់ចំណូលបន្ថែម ឬត្រូវធ្វើការខ្លាំងជាងមុនទៀតដើម្បីជៀសវាងការបាត់បង់ការងារ ។ លើសពីនេះទៀត សមាជិកគ្រួសាររបស់ពួកគេក៏ត្រូវបង្កើនបន្ទុកការងារដែរ ហើយពេលខ្លះ ត្រូវបង្កើនចំនួនសមាជិកគ្រួសារដែលចូលរួមក្នុងការរកចំណូល ។ សមាជិកគ្រួសារគ្រប់គ្នា បានបង្កើនបន្ទុកការងាររបស់ខ្លួន ដូចជា ការដាំដំណាំតាមផ្ទះ ការស្វែងរកម្ហូបអាហារពីធនធានទ្រព្យរួម ឬការងារផ្សេងៗទៀតដែលអាចធ្វើទៅបាន ។

### *ចំណាកស្រុក ពលកម្មកុមារ និងវត្តមាននៅសាលា*

នៅមិនទាន់មានភស្តុតាងបញ្ជាក់ច្បាស់ទេ ចំពោះការសន្មត់ថា កម្មករដែលបាត់បង់ការងារនៅទីក្រុង កំពុងនាំគ្នាទាំងហ្វូងវិលត្រលប់ទៅធ្វើការងារកសិកម្មនៅតាមទីជនបទវិញ ។ ជាក់ស្តែង ការពិភាក្សាតាមក្រុមស្នូល និងបទសម្ភាសពាក់កណ្ដាលរៀបរយជាមួយគ្រួសារនៅជនបទ បានបង្ហាញពីកំណើនចំនួន

---

៣ នៅត្រីមាសទី៤ ឆ្នាំ២០០៨ និង ត្រីមាសទី១ ឆ្នាំ២០០៩ ផលិតផលកសិកម្ម និងថាមពល បានធ្លាក់ថ្លៃខ្លាំង ប៉ុន្តែម្ហូបអាហារប្រចាំថ្ងៃមិនបានចុះថ្លៃទេ ទាំងនៅជនបទ និងទីក្រុង ។

អ្នកធ្វើចំណាកស្រុកទៅរកការងារនៅទីក្រុង បើទោះជាពួកគេដឹងថា ឱកាសរកបានការងារនៅទីក្រុង មានលក្ខណៈមិនប្រាកដប្រជាក៏ដោយ ។ រឿងនេះបង្ហាញថា ការងារធ្វើនៅជនបទ កាន់តែលំបាករកបានជាងនៅទីក្រុងទៅទៀត ។ ជាក់ស្តែង ក្នុងរយៈពេល ៦ខែមុននេះ ចំណាកស្រុកនៅភូមិកំពង់ឆ្នោត បានកើន ៣០-៤០% ហើយរំពឹងថា នឹងបន្តកើនឡើងនៅប៉ុន្មានខែខាងមុខ ។ ក្នុងករណីនេះ គេធ្វើចំណាកស្រុកទៅកាន់កំពង់សោម និងកោះកុង ដើម្បីរកចំណូលជួយផ្គត់ផ្គង់គ្រួសារ ។

ដើម្បីរស់រានបានក្នុងពេលដ៏លំបាកនេះ គ្រួសារងាយរងគ្រោះនៅជនបទ បានអោយកូនៗដែលកំពុងរៀនសូត្រ ជួយធ្វើការនៅក្នុងភូមិដើម្បីរកប្រាក់ចំណូលបន្ថែម ហើយគ្រួសារខ្លះបានឱ្យកូនៗឈប់ទៅសាលារៀន ដើម្បីអោយពួកគេទៅរកការងារធ្វើនៅក្រៅភូមិ ។ ក្នុងរយៈពេល ៦ខែកន្លងមកនេះ មានកុមារក្នុងអាយុពី ១៣-១៨ឆ្នាំ កាន់តែច្រើននាក់បានបោះបង់ការសិក្សាទៅរកការងារធ្វើនៅតាមទីក្រុង (ក្រុងភ្នំពេញ កំពង់សោម កោះកុង ឬកំពង់ចាម) ដោយធ្វើដូចជាអ្នកស៊ីឈ្នួលធ្វើការតាមផ្ទះ កម្មករកែច្នៃម្ហូបអាហារ កម្មករក្នុងចំការកសិកម្ម អ្នកបំរើតុភោជនីយដ្ឋាន ជាដើម ។ ការងារជាឧទាហរណ៍គួរកត់សម្គាល់មួយ គឺ ក្មេងស្រីជាច្រើនដែលធ្វើចំណាកស្រុកពីភូមិបាបោង ដូនវង្ស និង ប៉ៃលហែង បានទៅធ្វើការជាអ្នកស៊ីឈ្នួលតាមផ្ទះ ភាគច្រើននៅទីក្រុងភ្នំពេញ ហើយបានផ្ញើប្រាក់ទៅផ្ទះមួយចំនួន ។

### *ការខ្ចីបុល*

ក្រុមស្រាវជ្រាវរបស់ CDRI បានរកឃើញនូវកំណើនការខ្ចីប្រាក់សំរាប់ទិញអាហារ ដោយសារប្រាក់ចំណូលគ្រួសារ និងប្រាក់ផ្ញើពីកូនៗ បានធ្លាក់ចុះយ៉ាងខ្លាំង ។ មានគ្រួសារជាច្រើនបានធ្លាក់ខ្លួនយ៉ាងជ្រៅទៅក្នុងបំណុល ដោយសារការខ្ចីបុលពីអ្នករកស៊ីចងការប្រាក់ ឬអ្នកឱ្យខ្ចីស្រូវអង្ករ ក្នុងអត្រាការប្រាក់យ៉ាងខ្ពស់ដល់ ៥-៦% ក្នុង១ខែ ។ ម្យ៉ាងវិញទៀត នៅតាមគ្រប់ភូមិ លទ្ធភាពរកបានកម្ចីកាន់តែពិបាកឡើង ពីព្រោះអ្នកផ្តល់កម្ចី និងស្ថាប័នមីក្រូហិរញ្ញវត្ថុ បារម្ភថា ប្រជាជនមិនមានលទ្ធភាពសងបំណុលវិញ ។

## ៤. សន្និដ្ឋាន

គំរូតាងប្រើប្រាស់ក្នុងការវាយតម្លៃនេះ មានទំហំតូច ដូច្នេះគេពិបាកជាខ្លាំងនឹងធ្វើការសន្និដ្ឋានពី ផលប៉ះពាល់នៃ វិបត្តិសេដ្ឋកិច្ចសាកលទៅលើគ្រួសារជាទូទៅនៅកម្ពុជា ។ ទាក់ទងនឹងក្រុមគំរូតាងទាំងនេះ គេរកឃើញថា វិបត្តិសេដ្ឋកិច្ចសាកលមានផលប៉ះពាល់ធ្ងន់ធ្ងរ ទៅលើពលករងាយរងគ្រោះ មិនថាក្នុងវិស័យសេដ្ឋកិច្ចរៀបរយ ឬមិនរៀបរយក្តី ។ ក្នុងរយៈពេល ១២ខែ និង ៦ខែ កន្លងមកនេះ ចំនួនការងារធ្លាក់ចុះអស់ ៣០-៤០% ហើយប្រាក់ចំណូលក្នុងគ្រួសារ និងប្រាក់ផ្ញើទៅផ្ទះ បានធ្លាក់ចុះអស់ជាង ៥០% ។

វិបត្តិសេដ្ឋកិច្ចសាកល ជាកត្តាមួយក្នុងចំណោមកត្តាជាច្រើនទៀត ដែលបង្កការធ្លាក់ចុះកំរិតជីវភាពគ្រួសារនៅជនបទ ។ កត្តាទាំងនេះមានជាអាទិ៍ ទំនាស់ព្រំដែនជាមួយប្រទេសថៃ និងការធ្លាក់ថ្លៃផលិតផលកសិកម្មយ៉ាងគំហុក ដោយសារវិបត្តិហិរញ្ញវត្ថុសាកលដែលកើតមាននៅចុងឆ្នាំ២០០៨ បានធ្វើឱ្យធ្លាក់ចុះតំរូវការក្នុងពិភពលោក (Hossein 2009) ។ ការវាយតម្លៃរហ័សនេះបានបំពេញបន្ថែមលើការសិក្សាពីមុនៗ ដែលធ្វើឡើងដោយលោក Theng (2009 a, b) និងដែលបង្ហាញថា ការធ្លាក់ថ្លៃខ្លាំងនៃផលិតផលកសិកម្ម គឺជាកត្តាចំបងដែលរុញច្រានគ្រួសារនៅតាមជនបទ ឱ្យធ្លាក់ជ្រៅទៅក្នុងបំណុល និងភាពក្រីក្រ ក្នុងរយៈពេលពី ៦-១២ខែកន្លងទៅនេះ ។

គ្រួសារនានាបានប្រើយុទ្ធសាស្ត្រដោះស្រាយច្រើនបែបយ៉ាង ប៉ុន្តែចំនុចគួរឱ្យបារម្ភ គឺការប្រើកុមារក្នុងវ័យសិក្សា ឱ្យធ្វើការរកចំណូលនៅក្នុងភូមិ ។ កុមារទាំងនោះត្រូវខកខានទៅសាលាជាញឹកញាប់ នៅពេលត្រូវរកប្រាក់ចំណូល ហើយរឿងនេះបានប៉ះពាល់មិនល្អដល់ការសិក្សារបស់ពួកគេ ។ បញ្ហាអាក្រក់ជាងនេះទៀត គឺក្នុងអំឡុងពេល ៦ខែកន្លងមកនេះ មានកុមារជាច្រើន ត្រូវក្រុមគ្រួសារដកចេញពីសាលា ដើម្បីបញ្ជូនឱ្យទៅរកការធ្វើនៅក្រៅភូមិ ។ ជារឿយៗណាស់ ក្មេងស្រីៗត្រូវក្រុមគ្រួសារដកចេញពីសាលា ហើយបញ្ជូនទៅធ្វើជាអ្នកស៊ីឈ្នួលតាមផ្ទះ ឱ្យគ្រួសារអ្នកធូរធារ ដែលភាគច្រើននៅក្រុងភ្នំពេញ ។ទង្វើបែបនេះនឹងជះឥទ្ធិពលមិនល្អ ដល់ជីវភាពរស់នៅរបស់ពួកកុមារនៅថ្ងៃអនាគត ។ ពួកគេមានកំរិតអប់រំទាប និងមិនមានជំនាញអ្វីសោះ សំរាប់ទៅរកការងារ ដែលផ្តល់ប្រាក់កំរៃសមរម្យ ហើយត្រូវជាប់ផុងក្នុងភាពក្រីក្រតកូនតចៅ ។ ការជួយសង្គ្រោះពួកគេឱ្យចាកផុតភាពក្រីក្រ គឺជាបញ្ហាប្រឈមមួយធំណាស់ ៕


## ឯកសារយោង

Jalilian Hossein, Chan Sophal, Glenda Reyes, Saing Chang Hang (2009), The Global Financial Crisis and Developing Countries: *Cambodia* (Phnom Penh: CDRI)

Jalilian Hossein (2009), Food Price Changes and Their Consequences for Vulnerable Groups: What Lessons Can Be Learned? *Annual Development Review* (Phnom Penh: CDRI)

Kang Chandararot, Sok Sina, Kim Sedara, Liv Dannet. (2009), Rapid Assessment on the Impact of the Financial Crisis in Cambodia (Phnom Penh: CIDS)

Theng Vuthy (2009a). "Food and Financial Crises—Impact on Agriculture and Policy Priorities for Pro-Poor Agricultural Growth", *Cambodia Development Review,* March (Phnom Penh: CDRI)

Theng Vuthy (March 2009b), Managing through the Crisis—Strengthening Key Sectors for Cambodia's Future Growth, Development and Poverty Reduction: Agriculture and Rural Development. *Cambodia Outlook Brief*, CDRI and ANZ Royal Bank